ព្រះរាជាណាចក្រកម្ពុជា-136-

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ លើទី

លេខ : ០១ សរ

ចុះថ្ងៃទី២៥ ០៩ ១៩៩៨

សាលដីកា

លេខ : ១៤

ចុះថ្ងៃទី៣០ ០៤ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម បុណ្ណ ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រមរបាយការណ៍

៣ - លោក ទេវ៉ារ មួន ចៅក្រម

៤ - លោក ស៊ិន ឃឹម ចៅក្រម

៥ - លោក ជីវ កេង ចៅក្រម

៦ - លោក ប្រាក់ គឹមសាន ចៅក្រម

៧ - លោក សោម សិរីវឌ្ឍ ចៅក្រម

៨ - លោក យស់ សូខឿន ចៅក្រម

៩ - លោក ប៉ែន សារវឿន ចៅក្រម

ក្រឡាបញ្ជី

លោក ឃាង ប្រ៊ិន

តំណាងមហាអយ្យការ

លោក យួន បាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងលើទីរបស់ទណ្ឌិតអ៊ិន គឹមសាន ចុះថ្ងៃទី១០ ០៩ ១៩៩៨ តវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ១៦២ចុះថ្ងៃទី០៩ ០៤ ១៩៩៧របស់តុលាការខេត្តកំពង់ធំ និងសំណុំរឿងព្រហ្មទណ្ឌលើទីលេខ ០១ សរ ចុះថ្ងៃទី២៥ - ០៩ - ១៩៩៨ របស់តុលាការកំពូល ។

- ទណ្ឌិតឈ្មោះ អ៊ិន គឹមសាន "ម្ចាស់បណ្ដឹងលើទី" ភេទ ប្រុស អាយុ ៤៤ ឆ្នាំ ជាតិ ខ្មែរ របររកស៊ី មន្ត្រីសាលាស្រុកស្ទោងកើតនៅឆ្នាំ... ទៅសព្វថ្ងៃភូមិកំពង់រទេះ ឃុំ កំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោះ អ៊ិន ចេង "ស" ម្ដាយឈ្មោះ ម៉ី ហ៊ាន "ស" ទោសពីមុនគ្មាន ។ នៅក្រៅឃុំ ។

- មេធាវី គ្មាន

- ត្រូវចោទពីបទ ជេរប្រមាថប្រព្រឹត្តនៅភូមិ ឃុំកំពង់រទេះ ស្រុក ស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៧ ០៧ ១៩៩៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះកាន់ ដារិទ្ធ ភេទ ប្រុស អាយុ ៤៥ ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន សព្វថ្ងៃនៅភូមិ កំពង់រទេះ ស្រុកស្ទឹងសែន ខេត្ត កំពង់ធំ ។

- តាមពាក្យបណ្តឹងរបស់ឈ្មោះកាន់ ដារិទ្ធ បានប្តឹងថាកាលពីថ្ងៃទី១៧ .៧ .១៩៩៦ ឈ្មោះអ៊ុន គឹមសាន ដែលស្រែកជេរបញ្ចោរបរិហារប្រពន្ធខ្ញុំផង យ៉ាងអាសអាភាសនៅតាមវាលស្រែ ដោយមានអ្នកជិតខាងគេដឹងឮគ្រប់ៗគ្នា ។ សំណូមពរទាមទារជម្ងឺចិត្តជាប្រាក់ចំនួន១៥០ម៉ឺនរៀល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តកំពង់ធំថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះអ៊ុន គឹមសាន ពីបទៈជេរប្រមាថ អយ្យការរក្សាបទចោទនៅដដែល សូមតុលាការវិនិច្ឆ័យសេចក្តីទៅតាមច្បាប់ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦២ ចុះថ្ងៃទី០៩ - ០៤ - ១៩៩៧ របស់តុលាការខេត្ត កំពង់ធំ ដែលមានខ្លឹមសារសំរេចដូចតទៅ ៖

១ - សំរេចពិន័យឈ្មោះអ៊ុន គឹមសាន ជាប្រាក់៣០.០០០ រៀល ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ។ ពីបទជេរប្រមាថ ប្រព្រឹត្តនៅភូមិកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៧ .៧ - ១៩៩៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - អោយឈ្មោះអ៊ុន គឹមសាន ដូសជុលជម្ងឺចិត្តជាប្រាក់ចំនួន ២០ ម៉ឺនរៀល អោយទៅឈ្មោះកាន់ ដារិទ្ធ ជាដើមបណ្តឹងរដ្ឋប្បវេណី បណ្តឹងលើសពីនេះត្រូវលើកចោល ។ បើឈ្មោះអ៊ុន គឹមសាន ពុំព្រមសងតមទណ្ឌទេ ត្រូវបង្ខំដាក់គុកតាមច្បាប់ ស្តីពីការដាក់គុកបង្ខំរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ

៣ - សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសើរើចុះថ្ងៃទី១០ - ៩ - ១៩៩៨ របស់ទណ្ឌិតឈ្មោះ អ៊ុន គឹមសាន ប្តឹងពីសាលក្រមស្ថាពរលេខ ៦២ ចុះថ្ងៃទី ០៩ - ០៤ - ១៩៩៧ របស់តុលាការខេត្ត កំពង់ធំ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ តាមពាក្យបណ្តឹងរបស់ទណ្ឌិត អ៊ុន គឹមសាន ប្តឹងសើរើពុំមានភស្តុតាងច្បាស់លាស់តាមមាត្រា២៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌទេឡើយ ។

.បដិសេធពាក្យបណ្តឹងសើរើចុះថ្ងៃទី១០ - ០៩ - ១៩៩៨ របស់ទណ្ឌិត អ៊ុន គឹមសាន ចោលជាអសារបង់ ។

- បានស្តាប់ចម្លើយទណ្ឌិតឈ្មោះ អ៊ុន គឹមសាន បានអះអាងលើកឡើងនាពេលសវនាការថា៖ បានជាប្តឹងសើរើនេះ ដោយសារតុលាការខេត្តកំពង់ធំសំរេចបើកសវនាការជាលើកដំបូងអោយខ្ញុំចាញ់ធ្វើតាមសាក្សី ។

- ខ្ញុំពុំបានជេរប្រមាថអ្នកណាទេ ដទៃទៀតមានភស្តុតាងពីរដ្ឋអំណាចនិងសាក្សីខ្លះត្រូវវេត ច្បាស់ ដោយឡែកពេលឆ្លើយចំពោះមុខតុលាការខេត្តថា មួងខ្ញុំជេរប្រមាថ តែកាត់ក្រោយតាមដីកាចោទនេះថា៖ ខ្ញុំពុំបានជេរប្រមាថដើមបណ្តឹងទេឡើយ រហូតតុលាការខេត្តសំរេចដាក់គុកទៀតផង ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា៖ ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

- ក្រោយពីបានស្តាប់ចម្លើយរបស់ម្ចាស់បណ្តឹងសើរើ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសើរើចុះថ្ងៃទី១០ ខែកញ្ញាឆ្នាំ១៩៩៨ របស់ទណ្ឌិត ឈ្មោះ អ៊ិន គឹមសាន ប្តឹងសុំសើរើពីសាលក្រមព្រហ្មទណ្ឌលេខ១៦២ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៧របស់តុលាការខេត្ត កំពង់ធំ ធ្វើឡើងត្រឹមត្រូវតាមមាត្រា២២៧នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនិងតាមមាត្រា១៥ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញ លោកស្រីឈ្មោះអ៊ិន អ៊ុក និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះកាន់ ផារិទ្ធ ត្រូវបានអញ្ជើញមកតុលាការខេត្តកំពង់ធំ ចោទប្រកាន់ពីបទធ្វើសក្ខីកម្មក្លែងក្លាយនិងសមគំនិត ហើយ តុលាការក៏បានឃុំខ្លួនតាំងពីថ្ងៃទី១១ .១០ - ២០០១ រួចហើយ ។ដូច្នេះផ្អែកតាមគោលការណ៍នៃមាត្រា ២៣០នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌតុលាការកំពូលគប្បីទទួលបណ្តឹងសើរើទុកជាត្រឹមត្រូវតាមច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះ ម្ចាស់បណ្តឹង សើរើ

១ - ទទួលបណ្តឹងសើរើចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ទណ្ឌិតឈ្មោះអ៊ិនគឹមសាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២ - ផ្អាកការអនុវត្តសាលក្រមព្រហ្មទណ្ឌលេខ១៦២ចុះថ្ងៃទី០៩ខែមេសាឆ្នាំ ១៩៩៧ របស់តុលាការខេត្ត កំពង់ធំ ជាបណ្តោះអាសន្ន ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣០ខែ មេសា ឆ្នាំ ២០០៣ ។ល។